**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស**
លេខៈ ០០៦/១៧ [illegible]

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

នៅថ្ងៃសុក្រទី២៧ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង៨ និង៣០នាទីព្រឹក នៅវិមានសន្តិភាព មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៥ ដើម្បីឆ្លងៈ

**១- សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨។**

**២- សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦។**

៣- **បញ្ហាផ្សេងៗ៖** សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រីដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិបញ្ញត្តិលើ៖

៣.១ -កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការគេចវេសបន្លំពន្ធលើប្រាក់ចំណូល

៣.២- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការគេចវេសបន្លំពន្ធលើប្រាក់ចំណូល។

៣.៣- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះចៅស៊ុលតង់ និងយ៉ាង់ឌីពើរតួននៃប្រទេសព្រុយណេដារូសាឡឹម ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការគេចវេសបន្លំពន្ធលើប្រាក់ចំណូល។

៣.៤- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការគេចវេសបន្លំពន្ធលើប្រាក់ចំណូល។

៣.៥- ធម្មនុញ្ញមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC)។

ក្រោយពីបានស្តាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចអនុម័ត។

ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៤១ មហាវិថីសហព័ន្ធរុស្ស៊ី
ទូរសារលេខៈ ០២៣ ២១៦ ៨៤០, ទូរស័ព្ទៈ [illegible]
អ៊ីមែលៈ pressocm@gmail.com

## ១- សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨។

សេចក្តីព្រាងច្បាប់នេះ ត្រូវបានរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថាប័នទាំងអស់ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងគោលដៅដើម្បីបង្ហាញអំពីលទ្ធផលការងារដែលរាជរដ្ឋាភិបាលសម្រេចបាន នៅក្នុងឆ្នាំចុងក្រោយរបស់ រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភាឆ្ពោះទៅសម្រេចឱ្យបានជាអតិបរមានូវគោលដៅសំខាន់ៗ នៃកម្មវិធីនយោបាយរបស់រដ្ឋាភិបាល ជាពិសេសកម្មវិធីកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យដែលបាន និងកំពុងអនុវត្តយ៉ាងសស្រាក់សស្រាំតាំងពីដើមនីតិកាលមក ដើម្បីឆ្លើយតបទៅនឹងឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត។

នៅឆ្នាំ២០១៨ គឺជាឆ្នាំនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ផង និងជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ផង។ ដូចនេះរាជរដ្ឋាភិបាលត្រូវធានាឱ្យការបោះឆ្នោតទាំងពីរនេះប្រព្រឹត្តទៅដោយរលូន មានសណ្តាប់ធ្នាប់ ត្រឹមត្រូវ យុត្តិធម៌ និងដោយសេរី ទន្ទឹមនឹងការធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាទូទៅ ជាពិសេសការធានារក្សាការពារឱ្យបានដាច់ខាតនូវសន្តិភាព និងស្ថិរភាពសង្គមដែលបានមកដោយលំបាក ឱ្យស្ថិតស្ថេរគង់វង្សចីរកាល ក៏ដូចជាការបន្តទប់ស្កាត់រាល់ឧបាយកល និងការប៉ុនប៉ងតាមគ្រប់រូបភាពដែលមានគោលបំណងធ្វើឱ្យប្រទេសជាតិធ្លាក់ទៅក្នុងសភាពវឹកវរ និងអស្ថេរភាព។

ថវិកាថ្នាក់ជាតិឆ្នាំ២០១៨ បានបង្កើនទំហំចំណាយថវិការដ្ឋសរុបពី ១៣ ៤៧៥ ៩២៣ លានរៀល ឬសមមូលនឹង ៣ ៣៤៨លានដុល្លារអាមេរិក ដែលត្រូវជា ២១,៩៧%នៃផ.ស.ស ក្នុងឆ្នាំ២០១៣ ឡើងដល់ ២១ ១៥១៩៨៥លានរៀល ឬសមមូលនឹង ៥ ២៤០លានដុល្លារអាមេរិក ដែលត្រូវជា២៣,៦៣% នៃផ.ស.ស ក្នុងឆ្នាំ២០១៧ ហើយនឹងបន្តកើនឡើងដល់២៤ ៣៧៥ ១០២លានរៀល ឬសមមូលនឹង៦ ០៣៨លានដុល្លារអាមេរិក ដែលត្រូវជា២៤,៥៩%នៃផ.ស.ស នៅឆ្នាំ២០១៨ ពោលគឺចំណាយសរុបថវិការដ្ឋត្រូវបានបង្កើនជិតពីរដង។

ជាក់ស្តែង ទំហំសេដ្ឋកិច្ចជាតិ (ផ.ស.ស តាមថ្លៃបច្ចុប្បន្ន) បានកើនឡើងពី៦១ ៣២៦ ៩២៨លានរៀល ឬសមមូលនឹងប្រមាណជាង១៥២៣៧លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៣ ដល់ ៨៩៥០៩ ៤២២លានរៀលឬសមមូលនឹងប្រមាណជាង ២២១៧២ លានដុល្លារអាមេរិកក្នុងឆ្នាំ ២០១៧ ហើយនឹងបន្តឡើងដល់៩៩ ១១៦ ០៩១ លានរៀលសមមូលនឹងប្រមាណជាង ២៤ ៥៥២ លានដុល្លារអាមេរិកនៅឆ្នាំ២០១៨។

ចំណូលមនុស្សម្នាក់ធៀបនឹងផ.ស.បានកើនឡើងពី១០៤២ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៣ ដល់ប្រមាណ១៤៣៥ ដុល្លារអាមេរិកក្នុងឆ្នាំ២០១៧ ហើយនឹងបន្តឡើងដល់ប្រមាណ១៥៦៨ ដុល្លារអាមេរិកនៅឆ្នាំ២០១៨ ក្នុងខណៈដែលអត្រាប្តូរប្រាក់ស្ថិតនៅក្នុងរង្វង់៤០៥០រៀលក្នុងមួយដុល្លារអាមេរិក ហើយអត្រាអតិផរណាជាមធ្យមស្ថិតក្នុងរង្វង់៣% ដែលជាកម្រិតមួយទាប និងគ្រប់គ្រងបាននៅក្នុងរយៈពេលដូចគ្នា។

ទន្ទឹមនឹងនេះទុនបម្រុងអន្តរជាតិ ក៏បានកើនឡើងពី ៣៦៤៣ លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៣ដល់៧៥៣៩លានដុល្លារក្នុងឆ្នាំ២០១៧ ហើយនឹងបន្តឡើងដល់៧ ៩៨៣លានដុល្លារអាមេរិកនៅឆ្នាំ២០១៨។

គុណភាពជញ្ជីងទូទាត់ក៏មានភាពកាន់តែល្អប្រសើរឡើងជាលំដាប់ ក្នុងខណៈដែលកម្រិតបំណុលសាធារណៈរបស់កម្ពុជាមានអនុបាតបំណុលទាបបំផុតនៅក្នុងតំបន់ ដែលឆ្លុះបញ្ចាំងពីហានិភ័យទាប និងចីរភាពនៃបំណុលសាធារណៈរបស់កម្ពុជា។

ចំពោះអត្រានៃភាពក្រីក្របានធ្លាក់ចុះពីប្រមាណ៥៣,៥% ក្នុងឆ្នាំ២០០៩ មកត្រឹមតែប្រមាណ១៣,៥% ក្នុងឆ្នាំ២០១៤ និងបន្តកាន់តែធ្លាក់ចុះមកថែមទៀតនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះហើយមេគុណជីនីដែលបានធ្លាក់ចុះពី០,៣៨០ក្នុងឆ្នាំ២០០៩មកត្រឹម០,២៥៥ ក្នុងឆ្នាំ២០១៤ នោះក៏ត្រូវបានរំពឹងថាកាន់តែមានភាពប្រសើរឡើងថែមទៀតដែរ។ ប្រការនេះបានគូសបញ្ជាក់ថាកម្ពុជាមិនត្រឹមតែសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់និងរឹងមាំប៉ុណ្ណោះទេ តែកំណើននេះក៏កាន់តែមានបរិយាប័ន្ន ហើយការបែងចែកផលនៃកំណើនក៏កាន់តែមានសមធម៌ផងដែរ។ សមិទ្ធផលសង្គម-សេដ្ឋកិច្ចខាងលើនេះបានធ្វើឱ្យស្ថាប័នហិរញ្ញវត្ថុអន្តរជាតិចាត់ទុកកម្ពុជាជាប្រទេសមួយនៅក្នុងចំណោមប្រទេសឯកទត្តករកំណើនចំណាត់ថ្នាក់ទី៦នៅក្នុងពិភពលោក ដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ និងរឹងមាំ។ ជាងនេះទៅទៀត ធនាគារអភិវឌ្ឍន៍អាស៊ីក៏បានចាត់ទុកកម្ពុជាជាខ្លាសេដ្ឋកិច្ចថ្មីមួយនៅអាស៊ីផងដែរ។ ក្រៅពីនេះកម្ពុជាក៏ទទួលបាននូវជ័យលាភីជាច្រើនទៀតដូចជាការទទួលបានចំណាត់ថ្នាក់ជាប្រទេសជោគជ័យបំផុតទី៤ លើពិភពលោក ក្នុងការកាត់បន្ថយអត្រាភាពក្រីក្រ និងទទួលបានការវាយតម្លៃខ្ពស់ពីអង្គការសហប្រជាជាតិ ចំពោះការកាត់បន្ថយអត្រានៃភាពអត់ឃ្លានជាងពាក់កណ្តាលមុនពេលកំណត់ និងជាប្រទេសឈានមុខគេទាំង ៧ លើពិភពលោកក្នុងការកែលម្អសន្ទស្សន៍នៃការអភិវឌ្ឍមនុស្ស ក្នុងចន្លោះឆ្នាំ១៩៩០ ដល់ឆ្នាំ២០១៥។

ការសម្រេចនូវកំណើនសេដ្ឋកិច្ច និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក្នុងបរិការណ៍អតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាពខាងលើនេះ បានធ្វើឱ្យប្រជាជនកម្ពុជាគ្រប់ស្រទាប់ជាន់ថ្នាក់នៅទូទាំងប្រទេស កាន់តែមានឱកាសក្នុងការស្វែងរកការងារ និងក្នុងការបង្កើនប្រាក់ចំណូលដោយក្នុងនោះមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ទទួលបាននូវប្រាក់ចំណូលកាន់តែខ្ពស់ពីមួយឆ្នាំទៅមួយឆ្នាំតាមរយៈការអនុវត្តនូវគោលនយោបាយដំឡើងប្រាក់បៀវត្សក្នុងគោលដៅជាង១លានរៀលនៅឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាល។ ដូចគ្នានេះដែរកម្មករនិយោជិតរាប់សែននាក់ទៀតដែលកំពុងតែបម្រើការងារក្នុងវិស័យឯកជន ក៏ទទួលបាននូវឱកាសក្នុងការបង្កើនប្រាក់ចំណូលរបស់ខ្លួនផងដែរ តាមរយៈការអនុវត្តនូវគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការដំឡើងប្រាក់ឈ្នួលអប្បរមាជូនកម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងជារៀងរាល់ឆ្នាំ ដែលនឹងត្រូវកើនឡើងដល់ចំនួន១៧០ដុល្លារអាមេរិកនៅឆ្នាំ២០១៨ ដោយមិនទាន់គិតទៅដល់ការទទួលបាននូវអត្ថប្រយោជន៍ផ្សេងទៀត ពីការអនុវត្តគោលនយោបាយ គាំពារសង្គមរបស់រាជរដ្ឋាភិបាល។ ក្រៅពីការផ្តល់នូវឱកាសស្វែងរកការងារ និងឱកាសបង្កើនប្រាក់ចំណូលជូនដល់ប្រជាជនរាប់លាននាក់ខាងលើ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវវិធានការគោលនយោបាយចាំបាច់នានាជាបន្តបន្ទាប់ ក្នុងគោលដៅដោះស្រាយការលំបាក ក្តីកង្វល់ និងបំណងប្រាថ្នារបស់ប្រជាជនក៏ដូចជាដោះស្រាយបញ្ហាប្រឈមរបស់ជាតិ ទាំងបញ្ហាសង្គម និងបញ្ហាសេដ្ឋកិច្ច។ ជាក់ស្តែងការលុបចោលមិនយកកម្រៃពីសេវាសាធារណៈចាំបាច់មួយចំនួនបាន

ជួយសម្រាលបន្ទុកចំណាយ និងលើកកម្ពស់កម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង។ លើសពីនេះការដាក់ចេញនូវវិធានការបុរេសកម្មចាំបាច់នានាជាបន្តបន្ទាប់របស់រាជរដ្ឋាភិបាលទាំងក្នុងទិដ្ឋភាពនយោបាយ និងទាំងក្នុងទិដ្ឋភាពគោលនយោបាយពាក់ព័ន្ធនឹងការបញ្ចុះតម្លៃថាមពលអគ្គិសនី និងទឹកស្អាត ការបន្ធូរបន្ថយពន្ធ និងការអនុគ្រោះពន្ធលើប្រភេទពន្ធមួយចំនួនដូចជា៖ ការលុបចោលរបបពន្ធមៅការ ការដំឡើងកម្រិតអប្បរមានៃប្រាក់បៀវត្សត្រូវជាប់ពន្ធ ការលើកលែងពន្ធលើមធ្យោបាយដឹកជញ្ជូនសម្រាប់ទោចក្រយានយន្ត និងត្រីចក្រយានយន្តកម្លាំងក្រោម១៥០សេះ និងការលើកលែងពន្ធប្រថាប់ត្រាក្នុងរង្វង់សាច់ញាតិជាដើម បាននិងកំពុងតែផ្តល់ជាគុណប្រយោជន៍ដល់ប្រជាពលរដ្ឋទូទៅ ជាពិសេសអ្នកមានចំណូលទាប រួមទាំងមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ គ្រូបង្រៀន និងគ្រូពេទ្យ កម្មករនិយោជិត ក៏ដូចជាដល់ការប្រកបអាជីវកម្មតូចតាចផងដែរ។ ទន្ទឹមនឹងនេះការលុបចោលការបង់ភាស៊ី និងថ្លៃផ្សេងៗទៀត ចំពោះការលក់ដូររបស់ប្រជាពលរដ្ឋតាមកញ្ច្រែង កញ្ជើរ ល្អី នៅតាមទីផ្សារទូទាំងប្រទេស និងការអនុញ្ញាតឱ្យអាជីវករ ដែលមានតូប រាន ស្តង់ ឬកន្លែងលក់ដូរដទៃទៀត ទទួលបានសិទ្ធិកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផល ហើយអាចផ្ទេរសិទ្ធិបាន ព្រមទាំងលុបចោលពន្ធសត្តឃាត និងការគ្រប់គ្រងផ្តាច់មុខនៅក្នុងអាជីវកម្មសត្តឃាតដ្ឋាន បានចូលរួមចំណែកលើកកម្ពស់ជីវភាព និងកាត់បន្ថយបន្ទុកចំណាយរបស់ប្រជាពលរដ្ឋលើម្ហូបអាហារប្រចាំថ្ងៃបានមួយកម្រិតថែមទៀត ក៏ដូចជាបានជួយជំរុញធ្វើឱ្យសេដ្ឋកិច្ចជាតិ ជាពិសេស សេដ្ឋកិច្ចជនបទកាន់តែរីកចម្រើន។ ជារួម ការដាក់ចេញនូវវិធានការគោលនយោបាយពន្ធខាងលើ គឺដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងការជួយដោះស្រាយ និងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ។ ទោះជាយ៉ាងណាក្តី រាជរដ្ឋាភិបាលនៅតែអាចរក្សាបាននូវតួនាទីរបស់ប្រព័ន្ធពន្ធជាឃ្នាស់សម្រាប់ការការពារបាននូវការការប្រមូលចំណូល។ ម្យ៉ាងវិញទៀត ការសម្រេចទិញយកមកគ្រប់គ្រងវិញនូវគម្រោងផ្លូវ និងស្ពានមួយចំនួនជាបន្តបន្ទាប់ពីវិស័យឯកជននៅក្នុងក្របខ័ណ្ឌនៃយន្តការភាពជាដៃគូ រវាងរដ្ឋនិងវិស័យឯកជនក៏បានជួយដោះស្រាយការលំបាក និងជួយលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋបន្ថែមទៀតផងដែរ ក្រៅពីការសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋ។ ក្រៅពីនេះរាជរដ្ឋាភិបាលក៏បានបង្កើនចំណាយយ៉ាងច្រើនទៅលើការលើកកម្ពស់គុណភាព និងការពង្រីកវិសាលភាពសាធារណៈ ដើម្បីធ្វើឱ្យការផ្តល់សេវាសាធារណៈកាន់តែប្រសើរឡើង និងកាន់តែខិតជិតប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់។

សម្រាប់ឆ្នាំ២០១៨ ក្រៅពីបានដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធជាង១លានរៀល រាជរដ្ឋាភិបាលក៏បានគ្រោងថវិកាចំនួន ៣០ ០០០លានរៀល សម្រាប់រៀបចំជាមូលនិធិថែទាំសុខភាពជូនមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងនិវត្តជន។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានសម្រេចផ្តល់ និងដំឡើងប្រាក់ឧបត្ថម្ភគោលនយោបាយគាំពារសង្គមចំនួន២ទៀត ដោយអនុវត្តចាប់ពីខែមករាឆ្នាំ២០១៨ ដែលរួមមាន៖

- ផ្តល់ប្រាក់ឧបត្ថម្ភមាតុភាពដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទជាស្ត្រីដោយបង្កើនពី៦០០ ០០០ រៀលទៅចំនួន៨០០ ០០០រៀល សម្រាប់ការ

សម្រាលបានកូនមួយ និងចំនួន ១ ៦០០ ០០០រៀល សម្រាប់ការសម្រាលបានកូនភ្លោះពីរ និងចំនួន ២ ៤០០ ០០០ រៀល សម្រាប់ការសម្រាលបានកូនភ្លោះបី។

- ផ្តល់ប្រាក់ឧបត្ថម្ភបុណ្យសពមន្ត្រីរាជការស៊ីវិលដែលទទួលមរណភាព ដោយក្នុងម្នាក់ៗត្រូវបានដំឡើងពីចំនួន១ ២០០ ០០០រៀលទៅ២ ០០០ ០០០រៀលចំពោះមរណភាពដោយជម្ងឺធម្មតា និងដំឡើងពីចំនួន១ ៥០០ ០០០រៀល ទៅ៤ ០០០ ០០០រៀល ចំពោះមរណភាពក្នុងពេលបំពេញបេសកកម្ម ឬគ្រោះថ្នាក់ការងារ។

ទន្ទឹមនឹងនេះរាជរដ្ឋាភិបាលក៏បានកែសម្រួលនូវកម្រិតអប្បរមានៃប្រាក់បៀវត្សជាប់ពន្ធលើប្រាក់បៀវត្សដើម្បីអនុគ្រោះដល់មន្ត្រីរាជការ គ្រូបង្រៀន គ្រូពេទ្យ និងកម្មករនិយោជិតដែលទទួលប្រាក់បៀវត្សចាប់ពី ១ ២០០ ០០០រៀល ឬតិចជាងឱ្យរួចផុតពីការបង់ពន្ធលើប្រាក់បៀវត្ស។

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ មាន៦ជំពូក និង១៥មាត្រា។

## ២- សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦

សេចក្តីព្រាងច្បាប់នេះបង្ហាញពីលទ្ធផលនៃការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ក្រោមការដឹកនាំចង្អុលបង្ហាញ និងគាំទ្រជាប្រចាំដ៏ខ្ពង់ខ្ពស់របស់ សម្តេចតេជោនាយករដ្ឋមន្ត្រី ក្នុងឋានៈជាមេបញ្ជាការតែមួយនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយគោរពបានទាំងស្រុងទាំងកាលវសានត្តទាំងខ្លឹមសារតាមមាត្រា៧៨នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

លទ្ធផលនៃការអនុវត្តថវិកាឆ្នាំ២០១៦ រួមមាន៖

ចំណូលថវិការដ្ឋ (ថវិកាថ្នាក់ជាតិ និងថវិកាថ្នាក់ក្រោមជាតិ) អនុវត្តបានចំនួន ១៨៥១៥៧០៧,៩ លានរៀល ស្មើនឹង១០៥,១ % នៃច្បាប់ហិរញ្ញវត្ថុ។

សម្រាប់ការចំណាយថវិកាជាតិឆ្នាំ២០១៦ អនុវត្តបានចំនួន១៦៩២៧៩៤៥,៤ លានរៀល ស្មើនឹង ៩៦,៥% នៃច្បាប់ហិរញ្ញវត្ថុ ។

ប្រការនេះធ្វើឱ្យកម្ពុជាមាន អតិរេកនៃថវិកាក្នុងឆ្នាំ២០១៦មានចំនួន(+) ១៥២០១៦២,៥ លានរៀល។

ផ្អែកតាមតុល្យភាពចំណូលចំណាយបង្ហាញថា សេដ្ឋកិច្ចកម្ពុជានាឆ្នាំ២០១៦ សម្រេចបានកំណើនរឹងមាំក្នុងអត្រា៧% ដូចគ្នាទៅនឹងអត្រាកំណើនដែលបានព្យាករណ៍នាដើមឆ្នាំ២០១៦។ ភាពរឹងមាំនៃកំណើនសេដ្ឋកិច្ចនេះត្រូវបានជំរុញដោយកំណើននៃវិស័យឧស្សាហកម្មដែលនៅតែរឹងមាំ និងការងើបឡើងវិញនៃវិស័យកសិកម្ម ទោះបីវិស័យសេវាកម្មមានកំណើនយឺតបន្តិចក្តី។ ផ.ស.ស ជាតម្លៃបច្ចុប្បន្ន សម្រាប់ឆ្នាំ២០១៦ សម្រេចបានចំនួន ៨០ ៥៥៩ប៊ីលានរៀល ដែលផ.ស.ស សម្រាប់មនុស្សម្នាក់ៗបានកើនឡើងពី ១ ២១៥ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៥ ដល់ ១៣០២ ដុល្លារអាមេរិកក្នុងឆ្នាំ២០១៦។ អត្រាអតិផរណាមធ្យមប្រចាំឆ្នាំបានកើនឡើងបន្តិចពី ១,២% ក្នុងឆ្នាំ២០១៥ ដល់៣%ក្នុងឆ្នាំ២០១៦ ដោយសារតែការកើនឡើងនៃតម្លៃប្រេងឥន្ធនៈ និង

មួបអាហារនៅកម្ពុជា។ អត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំអាចនៅរក្សាបានក្នុងកម្រិត៤០៥៦រៀល ក្នុងមួយដុល្លារអាមេរិក។

ជារួមការអនុវត្តថវិកាឆ្នាំ២០១៦បានឆ្លើយតប និងផ្តល់ការគាំទ្រប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពដល់ការសម្រេចអាទិភាពគោលនយោបាយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ក៏ដូចជាក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ក្របខ័ណ្ឌថវិកា និងគោលនយោបាយថវិការបស់រាជរដ្ឋាភិបាល។

**៣- បញ្ហាផ្សេងៗ៖** អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានអនុម័តបញ្ជូនទៅសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិ នូវ ៖

៣.១ -កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការគិបកេងបន្លំពន្ធលើប្រាក់ចំណូល

៣.២- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការគិបកេងបន្លំពន្ធលើប្រាក់ចំណូល។

៣.៣- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះចៅស៊ុលតង់ និងយ៉ាំឌីពើរតួននៃប្រទេសប្រ៊ុយណេដារូសាឡឹម ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការគិបកេងបន្លំពន្ធលើប្រាក់ចំណូល។

៣.៤- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការគិបកេងបន្លំពន្ធលើប្រាក់ចំណូល។

៣.៥- ធម្មនុញ្ញមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC)។

សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន បាន៖

- ជុំរុញឱ្យក្រសួងការពារជាតិធ្វើការចែកអាវរងារជូនដល់កម្លាំងប្រដាប់អាវុធឈរជើងនៅតាមតំបន់ និងព្រំដែន ឱ្យបានទាន់មុនរដូវរងារចូលមកដល់។

- ណែនាំឱ្យថ្នាក់ដឹកនាំក្រសួងស្ថាប័ន ថ្នាក់ជាតិ និងអាជ្ញាធរថ្នាក់ក្រោមជាតិធ្វើការផ្សព្វផ្សាយអប់រំ ពន្យល់ឱ្យមន្ត្រីគ្រប់ជាន់ថ្នាក់ និងប្រជាពលរដ្ឋយល់ពីផលវិបាកនៃបដិវត្តន៍ពណ៌ដែលបង្កឡើងដោយក្រុមជនក្បត់ជាតិ ដោយបានឃុបឃិតជាមួយបរទេសសំដៅផ្តួលរំលំរដ្ឋអំណាចស្របច្បាប់ បង្កឱ្យប្រទេសជាតិធ្លាក់ចូលក្នុងភាពវឹកវរ អស្ថិរភាពនយោបាយ អន្តរាយដល់សុខសន្តិភាព និងបំផ្លិចបំផ្លាញដល់សេដ្ឋកិច្ចជាតិទាំងមូល។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង ១១ និង៤០ នាទី។

រាជធានីភ្នំពេញ, ថ្ងៃសុក្រ ទី ២៧ ខែ តុលា ឆ្នាំ ២០១៧